## Explaining how something works



កូន៖ ម៉ាក់! ម៉ាក់បង្រៀនខ្ញុំដេរឡេវតិចបានអេ៎?

ម៉ាក់៖ បានតាសកូន។ យកម្ជុលហើយខ្សែអំបោះម៉ោ។ ដំបូង ដោតខ្សែអំបោះចូលរន្ធម្ជុលឲ្យចូលសិនទៅ។

កូន៖ ចូលហើយម៉ាក់។ ហើយម៉េចទៀត?

ម៉ាក់៖ បន្ទាប់ម៉ោ ក្តួចខ្សែអំបោះនៅខាងចុង កុំឲ្យវារបូតចេញវិញ។ ចេះក្តួចអត់? ... មិនមែនអីចឹងអេ៎។ ចាំមើលអ៎ា ក្តួចអញ្ចេះ បានវាជាប់ល្អ។ ហើយបន្ទាប់ម៉ោ យើងយកឡេវមកដេរ។ កាន់ឡេវអញ្ចេះ កុំឲ្យជ្រុះ។ ហើយដេរពីលើចុះក្រោម ពីក្រោមឡើងលើអីចឹងទៅ។

កូន៖ រួចហើយម៉ាក់។ ដល់ពេលចុងក្រោយធ្វើម៉េចទៅ? កាត់យកម៉ងបានអេ៎?

ម៉ាក់៖ មានអ្នកណាកាត់យកម៉ង របូតខ្ចេចអស់ឥឡូវហ្នឹងហើយ។ យើងត្រូវក្តួចម្តងទៀតនៅខាងក្នុងខោ កុំឲ្យមើលពីក្រៅទៅឃើញ។ ក្តួចអញ្ចេះ ឃើញអត់? ... ចេះនៅ?

កូន៖ បាទ ចេះហើយ។

| | |
|---|---|
| អេ៎ | spoken form of the question or negation particle ទេ |
| តាស | particle confirming the preceding |
| ហើយម៉េចទៀត? | And then? |
| បន្ទាប់ម៉ោ [...] | And then [...] |
| មិនមែនអីចឹងអេ៎ | Not like this! |
| ចាំមើលអ៎ា | Look! / Have a look! – implying that she will demonstrate it |
| ដល់ពេលចុងក្រោយ | at the end, finally |
| យកម៉ង | = យកតែម្តង = without doing anything else |
| មានអ្នកណា | there's no-one who; this is a spoken form of មិនមាន[...] or គ្មាន[...] – contraction results in the negation not being audible anymore |
| ... ឥឡូវហ្នឹងហើយ | ... right away |

## Cultural notes

តើអ្នកចូលចិត្តឲ្យគេបង្រៀនធ្វើអ្វីមួយថ្មីដែលអ្នកមិនធ្លាប់ចេះដែរឬទេ? នៅខ្មែរ មានអ្នកឆ្លើយថា ចង់ឲ្យគេបង្រៀន ព្រោះយើងចេះកាន់តែច្រើនឡើង អាចធ្វើអ្វីៗដោយខ្លួនឯងបាន ប៉ុន្តែ

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.

អ្នកនឹងឮមានអ្នកឆ្លើយថា “ចេះច្រើន គេប្រើច្រើន”។ ឧទាហរណ៍ បើអ្នកចេះបើកឡាន អ្នកនឹងត្រូវគេឲ្យធ្វើតៃកុងកាន់តែញឹក បើអ្នកចេះជួសជុលកុំព្យូទ័រ នឹងមានមនុស្សកាន់តែច្រើន ដែលហៅអ្នកឲ្យមើលកុំព្យូទ័រដែលខូច។

| | |
|---|---|
| ឲ្យគេ ... | to let someone [do sth.], to have someone [do sth.] |
| ចេះច្រើន គេប្រើច្រើន | the more you know, the more task you are going to be assigned |
| តៃកុង | driver |

## Additional dialogue

ម៉ាក់៖ ម៉ោកូន ម៉ាក់បង្រៀនឆាលត។ ... បើកហ្គាសនៅ? ទុកឲ្យខ្ទះក្ដៅតិចសិនក៏បាន ហើយចាំដាក់ប្រេង។

កូន៖ ប្រេងប៉ុណ្ណឹងបានអេះម៉ាក់?

ម៉ាក់៖ ច្រើនជាងហ្នឹងតិច តិចបានហើយ។ ... ហ្នឹងហើយ។ ចាំឲ្យប្រេងក្ដៅតិចសិន ចាំដាក់លតចូល។ ហើយត្រលប់វាចុះឡើងឲ្យសព្វ។ ... ហ្នឹងហើយ ធ្វើអីចឹង។ ... ដៃម្ខាងទៀតទប់ខ្ទះឲ្យនឹង កុំឲ្យវាប៉ាក់ប៉ើក។ ហើយដៃស្ដាំកាន់វែកឲ្យចូលក្នុងតិច កុំកាន់នៅចុងពេក តែអីចឹងវាឆាប់ចុកដៃ ។

កូន៖ ឆាប៉ុណ្ណឹងបាននៅ ម៉ាក់?

ម៉ាក់៖ ហ្នឹងហើយ។ ហើយដាក់គ្រឿងទៅ។ ស្ករ ទឹកស៊ីអ៊ីវ អីហ្នឹង។

កូន៖ ម៉េចអត់ឡើងក្រហមដូចគេអីចឹងម៉ាក់?

ម៉ាក់៖ ម៉ោពីមិនទាន់ដាក់ប្រេងខ្យងហ្នឹងអាំ។ ណោះ ដាក់ស្រោចពីលើហ្នឹងតិចទៅ ហើយត្រលប់វាចុះឡើង ម៉ាសន្ទុះទៅ វាឡើងក្រហមហើយ។ ... ឃើញអត់?

កូន៖ ចាស។

| | |
|---|---|
| លត | kind of noodle (thick, about 2-3 cm long), usually stir-fried or used for desserts |
| ទុកឲ្យខ្ទះក្ដៅតិចសិន | let the pan get hot first |
| ប្រេងប៉ុណ្ណឹងបានអេះ? | That much oil, is that enough? |
| តិចបានហើយ | only a bit will be ok/enough/fine |
| ត្រលប់ចុះឡើង | keep stirring, keep turning over |
| ឲ្យសព្វ | all over, completely, fully |
| ធ្វើអីចឹង | you’re doing it right! |
| ប៉ាក់ប៉ើក | to shake (informal) |
| អីចឹងវាឆាប់ចុកដៃ | like this the hand gets tired quickly |
| ម៉េច ... អីចឹង? | Why is ... like this? |
| ឡើងក្រហម | to get redder |
| ម៉ោពី | spoken form of មកពី = because |
| ម៉ាសន្ទុះ | spoken form of មួយសន្ទុះ = for a while |

Copyright © 2017 www.aakanee.com – This document is provided under a Creative Commons Attribution-NonCommercial-ShareAlike 4.0 International License.